

ទិសដៅស្រាវជ្រាវនៅកម្ពុជា៖ ការកើនឡើងដៃគូនៅក្នុងដំណើរការតាក់តែងគោលនយោបាយ

កម្មវិធីពន្លកចំណេះ ជំណាក់កាលទី ២៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា សមិទ្ធិផលឆ្នាំ២០២៣–២០២៥

នៅទូទាំងស្ថាប័នរាជរដ្ឋាភិបាល ស្ថាប័ននានារបស់កម្ពុជាកំពុង**ស្វែងរកការស្រាវជ្រាវ និងបើកឱកាសឱ្យអ្នកស្រាវជ្រាវចូលរួមក្នុងការពិភាក្សាគោលនយោបាយ**។ ស្ថាប័នស្រាវជ្រាវ សាកលវិទ្យាល័យ និងអង្គការសង្គមស៊ីវិល កំពុងឆ្លើយតបជាមួយនឹងការបង្កើតទិន្នន័យ**កាន់តែអាចទុកចិត្តបាន កាន់តែមានបរិយាបន្ន និងងាយស្រួលប្រើប្រាស់ជាងមុន** ដែលបញ្ជាក់ពីនិន្នភាពនៃភាពជាដៃគូដើម្បីការអភិវឌ្ឍរបស់កម្ពុជានៅដំណាក់កាលបន្ទាប់។

១. រាជរដ្ឋាភិបាលកំពុងត្រូវការទិន្នន័យកាន់តែច្រើនឡើង

៤១

ស្ថាប័នរដ្ឋាភិបាលបានចូលរួម៖ ក្រសួងចំនួន ១៨ រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ១៨ និងសាកលវិទ្យាល័យសាធារណៈចំនួន ៥

១៨

ស្ថាប័នបានពិគ្រោះយោបល់ ឬស្នើសុំទិន្នន័យពីដៃគូស្រាវជ្រាវនៅកម្ពុជា

១៧

បញ្ហាគោលនយោបាយទទួលបានការចូលរួមជាប្រព័ន្ធរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិល តាមរយៈការពិភាក្សាផ្អែកលើទិន្នន័យ

ស្ថាប័នរដ្ឋាភិបាល កាន់តែច្រើនបានសហការជាមួយអ្នកស្រាវជ្រាវកម្ពុជា ដើម្បីទទួលបានទិន្នន័យជាក់ស្តែងទាន់ពេលវេលា ដោយផ្លាស់ប្តូរពីការពិគ្រោះយោបល់ម្តងម្កាល ទៅជាជាប់លាប់។

២. ទិន្នន័យកាន់តែអាចទុកចិត្តបាន និងកាន់តែមានបរិយាបន្ន

២៣% → ៦៥%

នៃឯកសារបោះពុម្ពផ្សាយ យ៉ាងហោចណាស់ ៣ក់កណ្តាលឆ្លើយតបទៅនឹងគោលការណ៍សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម

១៨% → ៣១%

នៃឯកសារបោះពុម្ពផ្សាយ ត្រូវបានដឹកនាំ និងសរសេរដោយអ្នកនិពន្ធទីមួយជាស្ត្រី

៩៤%

នៃការពិភាក្សាដែលបានវាយតម្លៃ បានបំពេញតាមស្តង់ដារអប្បបរមានៃគោលការណ៍ណែនាំស្តីពីការពិភាក្សាប្រកបដោយបរិយាបន្ន និងសៀវភៅណែនាំស្តីពីការស្រាវជ្រាវប្រកបដោយគុណភាព ដែលបានដាក់ឱ្យប្រើប្រាស់នៅឆ្នាំ២០២៥។

ទិន្នន័យដែលឆ្លុះបញ្ចាំងពីសំឡេងរបស់ ស្ត្រី ជនមានពិការភាព និងសហគមន៍ជនបទ បានផ្តល់ទិដ្ឋភាពកាន់តែពេញលេញដល់អ្នកធ្វើសេចក្តីសម្រេចចិត្តអំពីក្រុមដែលរងផលប៉ះពាល់ដោយសារគោលនយោបាយរបស់គាត់។

៣. អ្នកស្រាវជ្រាវជំនាន់ក្រោយនៅកម្ពុជា

៧២

យុវជនទទួលបានការគាំទ្រ៖ និស្សិតថ្នាក់បរិញ្ញាបត្រ ៣០ នាក់ អ្នកស្រាវជ្រាវវ័យក្មេង ១២ នាក់ និងអ្នកស្រាវជ្រាវមានបទពិសោធន៍ការងារកម្រិតមធ្យម ៣០ នាក់

៥៤%

នៃអ្នកស្រាវជ្រាវវ័យក្មេងក្រោម គម្រោងគោលនយោបាយបរិយាបន្នមកពីក្រុមដែលងាយរងគ្រោះ រួមមាន ជនជាតិដើមភាគតិច ក្រុមអ្នកស្រលាញ់ភេទដូចគ្នា និងជនមានពិការភាព

៣៦

ទទួលបានការគាំទ្រតាមរយៈ អាហារូបករណ៍ ការប្រឹក្សាណែនាំ និងបណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ

វិស័យស្រាវជ្រាវដែលប្រកបដោយចីរភាពពឹងផ្អែកលើធនធានមនុស្ស៖ អ្នកស្រាវជ្រាវទាំងនេះកំពុងកសាងជំនាញ និងបណ្តាញទំនាក់ទំនង ដើម្បីរួមចំណែកដល់ការពិភាក្សាគោលនយោបាយរបស់កម្ពុជានាពេលអនាគត ។

ការចូលរួមផ្តល់ទិន្នន័យដល់ដំណើរការគោលនយោបាយរបស់រាជរដ្ឋាភិបាល

ចាប់តាំងពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥ ដៃគូស្រាវជ្រាវនៅកម្ពុជាបានចូលរួមក្នុងការស្រាវជ្រាវ និងការពិភាក្សាប្រកបដោយបរិយាបន្ន ដែលរួមចំណែកដល់**ដំណើរការគោលនយោបាយដែលដឹកនាំដោយរាជរដ្ឋាភិបាលចំនួន ១១ នៅ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** ដែលគ្របដណ្តប់លើគោលនយោបាយចំនួន ១០ តាមការអញ្ជើញរបស់ក្រសួង អាជ្ញាធរថ្នាក់ខេត្ត និងក្រុមប្រឹក្សាឃុំសង្កាត់ ដូចខាងក្រោម៖

- ការអភិវឌ្ឍជនបទ
- ការអប់រំ និងជំនាញ
- ការគាំពារសង្គម និងភាពធន់នឹងអាកាសធាតុ
- កសិកម្ម និងស្រូវអង្គរ
- ការរៀបចំថវិកាឃុំសង្កាត់សម្រាប់អាកាសធាតុ
- ស្ថិតិជាត
- ទឹកស្អាត អនាម័យ និងភាពធន់នឹងអាកាសធាតុ
- ការងារ និងពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់មកវិញ
- សហគ្រាសធុនមីក្រូ តូច និងមធ្យម
- រដ្ឋបាលសាធារណៈ និងទិន្នន័យបើកចំហ

www.policypulse.org · policypulse@asiafoundation.org
@PonlokChomnes on Facebook, X and LinkedIn

លទ្ធផលបូកសរុបចាប់ពីខែកក្កដា ឆ្នាំ២០២៣ ដល់ខែធ្នូ ឆ្នាំ២០២៥ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។ កម្មវិធីពន្លកចំណេះដំណាក់កាលទី ២៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា ទទួលបានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី និងអនុវត្តដោយអង្គការមូលនិធិអាស៊ី។

បរិយាបន្នភាពនៅក្នុងការអនុវត្ត

ទិន្នន័យដែលរួមចំណែកដល់ការសម្រេចចិត្តសម្រាប់ប្រជាជនកម្ពុជាទាំងអស់ត្រូវតែរួមបញ្ចូលទាំងសំឡេងរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។

វាគ្មិនដែលមានពិការភាពនិងមន្ត្រីរាជរដ្ឋាភិបាលបានចូលរួមនៅក្នុងការពិភាក្សាគោលនយោបាយប្រកបដោយបរិយាបន្នពិការភាព របស់កម្មវិធីពន្លកចំណេះ។



ការពិភាក្សាប្រកបដោយបរិយាបន្ន

៦៣
ការពិភាក្សា (កម្រិតថ្នាក់ជាតិ ៥០ និងកម្រិតថ្នាក់ក្រោមជាតិ ១៣)

៤,៨៥៣
អ្នកចូលរួម

៤១%
អ្នកចូលរួមជាស្ត្រី

ការពិភាក្សាដែលមានវាគ្មិនជាស្ត្រី ៦៥% (៤១/៦៣)

ការពិភាក្សាដែលមានវាគ្មិនដែលមានពិការភាព ១៦% (១០/៦៣)

ការពិភាក្សាដែលស្របតាមស្តង់ដារបរិយាបន្ន ៩៤% (៣៤/៣៦)

បរិយាបន្ននាពេលបច្ចុប្បន្នត្រូវបានគ្រោងឡើងតាំងពីពេលចាប់ផ្តើមការពិភាក្សានីមួយៗ មិនមែនបន្ថែមនៅនាទីចុងក្រោយនោះទេ។

ស្ត្រីក្នុងការស្រាវជ្រាវ និងភាពជាអ្នកដឹកនាំ

ស្ត្រីជាអ្នកនិពន្ធទីមួយ ៣១% (១៩/៦២)

ស្ត្រីជាវាគ្មិន ៣៧% (១១៧/៣១៥)

ស្ត្រីជាអ្នកចូលរួម ៤១% (១,៩៨២/៤,៨៥៣)

បណ្តាញស្ត្រីនៅក្នុងវិស័យស្រាវជ្រាវភ្ជាប់ទំនាក់ទំនងអ្នកស្រាវជ្រាវស្ត្រីនៅបណ្តាស្ថាប័ននានាតាមរយៈ ការតម្រង់ទិស ជំនួយឧបត្ថម្ភសម្រាប់ការស្រាវជ្រាវ និងការពិភាក្សាគោលនយោបាយ។

ស្ត្រីកំពុងផ្លាស់ប្តូរពីតួនាទីពីអ្នកចូលរួម ទៅជាអ្នកនិពន្ធ និងវាគ្មិន ដែលដឹកនាំការស្រាវជ្រាវ និងការពិភាក្សា។

ជនមានពិការភាព

១៣
វាគ្មិន

៧៣
អ្នកចូលរួម

៤
អ្នកសម្របសម្រួល

៧៥%
នៃការពិភាក្សាធ្វើឡើងនៅទីតាំងដែលបង្កលក្ខណៈងាយស្រួល

បរិយាបន្នពិការភាពគឺជាអាទិភាពរបស់យើងដែលបន្តពង្រឹង៖ ជនមានពិការភាពចំនួន ១.៥% បានចូលរួម។ ឯកសារជាអក្សរស្ទាប (Braille) ការបកប្រែភាសាសញ្ញា និងទីតាំងដែលបង្កលក្ខណៈងាយស្រួល ឥឡូវនេះក្លាយជាស្តង់ដារសម្រាប់កម្មវិធីសំខាន់ៗ។

ជនមានពិការភាព កំពុងចូលរួមជាវាគ្មិន អ្នកសម្របសម្រួល និងអ្នកស្រាវជ្រាវ មិនមែនត្រឹមតែជាប្រធានបទនៃការស្រាវជ្រាវនោះទេ។

ទិន្នន័យដែលបានទៅដល់ប្រជាជនទូទៅ

១.៧៧ លាន ដង
ការចូលមើលកម្មវិធីគំនិតតូចជាភាសាខ្មែររបស់វេទិកាអនាគត

៤០១,០០០ ដង
ការចូលមើលនៅលើហ្វេសប៊ុក (organic views)

៦៧,០០០ នាក់
គេហទំព័រ Policy Pulse មានអ្នកប្រើប្រាស់

១៦
អត្ថបទព័ត៌មាន នៅក្នុងសារព័ត៌មានថ្នាក់ជាតិចំនួន ៨

គេហទំព័រស្រាវជ្រាវដែលបំពេញតាមលក្ខណៈវិនិច្ឆ័យនៃភាពងាយស្រួលចូលប្រើប្រាស់ ៤៦%

ការស្រាវជ្រាវជាភាសាខ្មែរ និងទម្រង់ដែលមានផាសុកវត្ថុ កំពុងទៅកាន់ដល់ក្រុមគោលដៅជាច្រើន លើសពីក្រុមអ្នកតាក់តែងគោលនយោបាយ។

អំពីកម្មវិធីពន្លកចំណេះដំណាក់កាលទី ២៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា

- **គោលបំណង៖** គាំទ្រស្ថាប័នក្នុងស្រុកដើម្បីផលិត និងប្រើប្រាស់ទិន្នន័យដែលអាចទុកចិត្តបាន និងមានបរិយាបន្ន ក្នុងគោលនយោបាយសាធារណៈ (កម្មវិធីពន្លកចំណេះដំណាក់កាលទី១ ឆ្នាំ២០១៩-២០២៣ កម្មវិធីពន្លកចំណេះដំណាក់កាលទី២ ឆ្នាំ២០២៣-២០២៧)។
- **ដៃគូ៖** ដៃគូកម្ពុជាចំនួន ២៥ (ដៃគូយុទ្ធសាស្ត្រចំនួន ៤ ដៃគូនវានុវត្តន៍ចំនួន ៨ ដៃគូសហការចំនួន ៤ ដៃគូសហការគោលនយោបាយចំនួន ៩) ក្រុមអ្នកជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងបណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ។
- **អភិបាលកិច្ច៖** គណៈកម្មាធិការប្រឹក្សាផ្នែកបច្ចេកទេស ដែលមានតំណាងជាន់ខ្ពស់មកពីស្ថាប័នចំនួន ១៣ រួមមាន ក្រសួងរាជរដ្ឋាភិបាល អ្នកជំនាញ និងសង្គមស៊ីវិល ដែលផ្តល់យោបល់លើយុទ្ធសាស្ត្រ។
- **លទ្ធផល៖** វិស័យស្រាវជ្រាវមួយដែលកាន់តែអាចទុកចិត្តបាន កាន់តែមានបរិយាបន្ន និងកាន់តែមានទំនាក់ទំនងស៊ីជម្រៅជាមួយរាជរដ្ឋាភិបាល។
- **ការគាំទ្រ៖** ទទួលបានការគាំទ្រថវិកាពីរដ្ឋាភិបាលអូស្ត្រាលី និងអនុវត្តដោយអង្គការមូលនិធិអាស៊ី។

ដំណើរឆ្ពោះទៅមុខ៖ តើអ្វីខ្លះដែលនឹងបន្តនិរន្តភាពសមិទ្ធផលទាំងនេះ ឆ្ពោះទៅឆ្នាំ២០៣០?

ទិន្នន័យសម្រាប់គោលនយោបាយ
ទិន្នន័យត្រូវបានស្នើសុំ និងប្រើប្រាស់ជាប្រចាំ

ហិរញ្ញប្បទានវិស័យស្រាវជ្រាវ
ប្រភពហិរញ្ញប្បទានចម្រុះ រួមទាំងការស្រាវជ្រាវដើម្បីប្រយោជន៍សាធារណៈ

អ្នកស្រាវជ្រាវជំនាន់ក្រោយ
អាជីពការងារស្រាវជ្រាវដែលទាក់ទាញ និងរក្សាបានធនធានមនុស្សចម្រុះភាព

ប្រព័ន្ធអេកូឡូស៊ីវិស័យស្រាវជ្រាវ
វេទិកាមួយជាកម្មសិទ្ធិរបស់កម្ពុជា ដែលភ្ជាប់ការស្រាវជ្រាវ និងរាជរដ្ឋាភិបាល

www.policypulse.org · policypulse@asiafoundation.org
@PonlokChomnes on Facebook, X and LinkedIn

Australian Aid · PONLOK CHOMNES · The Asia Foundation